ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

# សេចក្ដីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋបារាំង សូមជម្រាបជូនប្រជាពលរដ្ឋ សិស្ស និងនិស្សិតខ្មែរទាំងអស់ មេត្តាជ្រាបថា រដ្ឋាភិបាលបារាំងបានអនុវត្តវិធានការរឹតបន្តឹងការធ្វើដំណើរ ចេញ-ចូលប្រទេសបារាំង ចាប់ពីថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២១ ដូចតទៅ៖

- ហាមឃាត់ការធ្វើដំណើរចេញ-ចូលប្រទេសបារាំង ដល់ប្រទេសទាំងឡាយណា ដែលពុំស្ថិតក្នុងតំបន់អឺរ៉ុប (Espace Européen) លើកលែងតែករណីបន្ទាន់ តែតម្រូវឱ្យមានលិខិតបញ្ជាក់ពីមូលហេតុ និងឯកសារយោង។
- អ្នកដំណើរតាមគ្រប់មធ្យោបាយធ្វើដំណើរទាំងអស់ ដែលចាកចេញពីប្រទេសបារាំងទៅកាន់ប្រទេសនៃតំបន់អឺរ៉ុប ឬមកពីប្រទេសនៃតំបន់អឺរ៉ុប ចូលមកប្រទេសបារាំង និងដែលមានអាយុចាប់ពី ១១ឆ្នាំ ឡើងទៅ ត្រូវបង្ហាញលទ្ធផលតេស្តគ្មានជំងឺកូវីដ-១៩ ទាំងពេលចូល និងពេលចាកចេញ។

សម្រាប់ព័ត៌មានលម្អិតស្ដីពីប្រភេទមូលហេតុ ឯកសារយោង បញ្ជីឈ្មោះប្រទេសនៃតំបន់អឺរ៉ុប និងករណីលើកលែងផ្សេងៗ សូមចូលទៅកាន់គេហទំព័រក្រសួងមហាផ្ទៃបារាំង https://www.interieur.gouv.fr/Actualites/L-actu-du-Ministere/Attestation-de-deplacement-et-de-voyage#from4 ។

ក្នុងករណីបន្ទាន់ សូមទាក់ទងមកស្ថានទូតតាមលេខទូរស័ព្ទ (+33) 1 45 03 47 20 ឬលោក **សាលី ម៉ាលីវ៉ាត់** កុងស៊ុល (+33) 7 68 999 408 និងអាសយដ្ឋានអ៊ីម៉ែល arc@ambcambodgeparis.info ។ ២

ថ្ងៃចន្ទ ៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ប៉ារីស ថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០២១

4, rue Adolphe Yvon
75116 – PARIS (France)
Tel. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40